**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

លេខ ១០៧១/០៧ គ.ជ.ប

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**ជំរាបជូន**
**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងព័ត៌មាន**

**កម្មវត្ថុ** : ការផ្សព្វផ្សាយព័ត៌មានសមធម៌ ក្នុងអំឡុងពេលឃោសនាបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ២

**យោង** : - បទបញ្ជា និងនីតិវិធី គ.ជ.ប សម្រាប់ការបោះឆ្នោតឃុំ សង្កាត់ អាណត្តិទី ២ ឧបសម្ព័ន្ធទី ៧ ស្តីពី គោលការណ៍សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

- ស្មារតីអង្គប្រជុំ គ.ជ.ប នៅថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០០៧

តាមកម្មវត្ថុ និងយោងខាងលើ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សូមជម្រាបឯកឧត្តមរដ្ឋមន្ត្រីជ្រាបថា ក្នុងការឃោសនាបោះឆ្នោតឃុំ សង្កាត់ អាណត្តិទី ២ នេះ គ.ជ.ប បានផ្តល់ឱកាសឱ្យគណបក្សនយោបាយមានសិទ្ធិផ្សព្វផ្សាយគោលនយោបាយរួមរបស់ខ្លួន តាមទូរទស្សន៍ និង វិទ្យុរដ្ឋ និងបានផ្តល់សិទ្ធិដល់អង្គការមិនមែនរដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានបានរៀបចំកម្មវិធីសំនួរចម្លើយ ឬពិភាក្សាអំពីគោលនយោបាយគណបក្ស ដើម្បីផ្សព្វផ្សាយក្នុងអំឡុងពេលឃោសនាបោះឆ្នោតនេះ ។ ថ្មីៗនេះ គ.ជ.ប បានឯកភាពលើ កម្មវិធីព័ត៌មានសមធម៌ ដែលរៀបចំឡើងដោយក្រសួងព័ត៌មាន (ទូរទស្សន៍ជាតិកម្ពុជា) រួមសហការជាមួយ UNDP ។ ជាពិសេសការបែងចែកនាទីសម្រាប់គណបក្សនយោបាយទាំង ១២ ដែលបានចូលរួមការបោះឆ្នោត ដោយគណបក្សនយោបាយនីមួយៗ ទទួលបានចំនួននាទីក្នុងកម្មវិធីនោះ រួមមាន: គណបក្សប្រជាជនកម្ពុជា ៣ នាទី ៤៨ វិនាទី គណបក្សហ៊្វុនស៊ិនប៉ិច ២ នាទី គណបក្សសមរង្ស៊ី ២ នាទី ៦ វិនាទី គណបក្សនរោត្តមរណឫទ្ធិ ១ នាទី ៦ វិនាទី និងគណបក្សនយោបាយ ៨ ទៀតទទួលបានរួមគ្នា ១ នាទី ។ សរុបជារួមព័ត៌មានសមធម៌នេះផ្សាយរយៈពេល ១០ នាទី ក្នុងមួយថ្ងៃ ។

អាស្រ័យដូចបានជំរាបជូនខាងលើ សូមឯកឧត្តមរដ្ឋមន្ត្រី ជ្រាបជាព័ត៌មាន ។

សូមឯកឧត្តមទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

ភ្នំពេញ, ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៧

ជ. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ប្រធាន

អ៊ឹម សួស្ដី